


# ពូជស្រូវក្រអូប "ផ្ការំចេក"

ពូជ "ផ្ការំចេក" ជាពូជស្រូវក្រអូបដែលបានធ្វើការរំដោះ និងផ្សព្វផ្សាយដោយវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជានាឆ្នាំ ១៩៩៩។ បច្ចុប្បន្នពូជស្រូវ "ផ្ការំចេក" បាននឹងកំពុងពេញនិយមក្នុងចំណោមប្រជាកសិករនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយពូជស្រូវនេះផ្តល់នូវទិន្នផលខ្ពស់ គុណភាពអង្ករល្អមានភាពថ្លាវែងរលូន បាយទន់ឆ្ងាញ់ថែមទាំងមានក្លិនក្រអូបទៀតផង។ ជាពិសេសទៅទៀត ជាពូជដែលមានប្រភេទអង្ករមានតំលៃខ្ពស់នៅលើទីផ្សារជាតិ និងអន្តរជាតិ។

## លក្ខណៈពិសេសៗរបស់ពូជស្រូវផ្ការំចេក

ពូជ "ផ្ការំចេក" ជាពូជស្រូវដែលមាន វេទរសភាពនឹងខួបពន្លឺ "ប្រកាន់រដូវ "មធ្យម។ វាចាប់ចេញផ្កាពីចុងខែតុលា អាស្រ័យទៅលើអាកាសធាតុ និងពេលវេលាដាំដុះ។ កំពស់ដើមរបស់ពូជស្រូវ "ផ្ការំចេក" ប្រែប្រួលពី ១១២-១៦៣ ស.ម និងចំនួនដើមបែកគឺចាប់ពី ៥-១០ ដើម ក្នុងមួយគុម្ព អាស្រ័យទៅតាមប្រភេទដី។ ចំនួនគ្រាប់ក្នុងមួយកួរមានចាប់ពី ១០៦-១៤៦ គ្រាប់ និងមានប្រវែងកួរ ១៦-២៨ ស.ម។ រីឯទិន្នផលរបស់វាវិញគឺអាចទទួលបានចាប់ពី ៣,០ តោន ទៅ ៥,០ តោន ក្នុងផ្ទៃដី ១ ហិកតា។

## វិធីសាស្រ្តដាំដុះ

- ប្រើប្រាស់គ្រាប់ពូជដែលសុទ្ធល្អ និងមានអត្រាដំណុះខ្ពស់។
- បរិមាណគ្រាប់ពូជចាំបាច់ ៣០-៥០ គ.ក្រ ក្នុង ១ ហិកតា សំរាប់ស្រូវសន្ទូង និង ៨០-១២០ គ.ក្រ ក្នុង ១ ហិកតា សំរាប់ស្រូវពង្រួស។
- ទីសំណាបត្រូវធ្វើនៅជិតប្រភពទឹក តែត្រូវឆ្ងាយពីម្លប់ព្រៃ ឬ កន្លែងមានភ្លើងអគ្គិសនី ដើម្បីចៀសវាងការបំផ្លាញពីសត្វល្អិតចង្រៃ។
- ផ្ទៃដីសំរាប់សាបគឺ ១ គីឡូក្រាម ក្នុងផ្ទៃដី ១៥-២០ ម៉ែត្រការ៉េ។
- ជាការល្អគួរស្ទូងសំណាបដែលមានអាយុ ២៥-៣០ថ្ងៃ ហើយក្នុង ១គុម្ព ២-៣ ដើម។
- គួររៀបចំដីអោយបានល្អមុនស្ទូង។ ការភ្ជួររាស់ គួរតែធ្វើអោយបាន ២-៣សារ ជាការល្អ។

⊙ បើសិនស្រែយើងអាចបញ្ចេញបញ្ចូលទឹកបាន ពេលស្រូវបែកគុម្ពត្រូវបញ្ចេញទឹកអោយអស់ពីក្នុងស្រែ ២-៤ថ្ងៃ រួចបញ្ចូលទឹកថ្មីវិញ។ នេះគឺដើម្បីធ្វើអោយស្រូវកាន់តែបែកគុម្ពល្អ។






# ការប្រើប្រាស់ជី

ការប្រើប្រាស់ជីសមស្របតាមការិតណែនាំ នឹងមិនបណ្តាលអោយមានការថយចុះ ឬបាត់បង់ក្លិន ឬគុណភាពដទៃទៀតឡើយ ។



### គួរដាក់ជី ២-៣ ដងក្នុង ១ វដ្តជីវិតរបស់ស្រូវ

- **បាចលើកទី១ :** ទ្រាប់បាតមុនពេលស្ទូង ប្រើជីធម្មជាតិ ពី ៥-១០ តោន/ហ.ត និងរួមផ្សំជាមួយជីគីមី ដូចមានក្នុងតារាងខាងក្រោម ។
- **បាចលើកទី២ :** បំប៉ន ៣០ ថ្ងៃក្រោយពេលស្ទូង ប្រើជីអ៊ុយរ៉េ ការិតដូចមានក្នុងតារាងខាងក្រោម ( ក្នុងដំណាក់កាលបែកគុម្ព ) ។
- **បាចលើកទី៣ :** បំប៉ន នៅមុនពេលចេញផ្កា ៣៥ ថ្ងៃ ( ក្នុងដំណាក់កាលកកើតកួរ ) ប្រើជីអ៊ុយរ៉េ ការិតដូចមានក្នុងតារាងខាងក្រោម ។

| ប្រភេទបាច/ហ.ត / ប្រភេទដី | ប្រភេទជី | ទ្រាប់បាត (គ.ក្រ/ហ.ត) | បំប៉នលើកទី១ (គ.ក្រ/ហ.ត) | បំប៉នលើកទី២ (គ.ក្រ/ហ.ត) |
|---|---|---|---|---|
| ដីខ្សាច់ ( ដីព្រៃខ្មែរ , ប្រទះឡាង ) | អ៊ុយរ៉េ | ១៦-៣១ | ៣៥-៨៧ | ២៦-៦៦ |
| | ដេអាប៉េ | ២៦-៨៧ | 0 | 0 |
| | ប៉ូតាស | ១00-១៣៣ | 0 | 0 |
| ដីល្បាយឥដ្ឋ ( ដីបាកាន, អូរូង, ទួលសំរោង, គោកត្រប់, ក្រគរ ) | អ៊ុយរ៉េ | ២៧-៥២ | ១0៥ | ៦0-៧៩ |
| | ដេអាប៉េ | ៥៥-១៣0 | 0 | 0 |
| | ប៉ូតាស | 0-៦៧ | 0 | 0 |
| ដីឥដ្ឋ ( ដីកំពង់សៀម, ក្បាលពោធិ , កៀនស្វាយ ) | អ៊ុយរ៉េ | ៥0-៥៣ | ៧0-៨៧ | ៥៣-៦៦ |
| | ដេអាប៉េ | 0-៣៩ | 0 | 0 |
| | ប៉ូតាស | 0 | 0 | 0 |

## ការប្រមូលផល

- ត្រូវធ្វើការច្រូតកាត់នៅរវាង ៣0-៣៥ ថ្ងៃ បន្ទាប់ពីស្រូវហាលផ្កាស្រុះ ឬពេលដែលប្រមាណ ៨៥ ភាគរយ នៃគ្រាប់ស្រូវទុំ ។
- ត្រូវហាល ២-៣ ថ្ងៃ ដើម្បីបន្ថយសំណើមនៅក្នុងគ្រាប់អោយនៅ ១៤ ភាគរយ មុននឹងទុកជាការល្អ ។ សូមយកគ្រាប់ស្រូវមកខាំដើម្បីកំណត់បើគ្រាប់ស្រូវនោះបាក់ គឺមានន័យថាគ្រាប់ស្រូវស្ងួតល្អ ។
- ពូជត្រូវច្រកទុកនៅក្នុងបាវក្រចៅជាការប្រសើរ
- ការទុកដាក់ពូជត្រូវមានកំណល់មិនត្រូវដាក់បាវពូជផ្ទាល់នឹងឥដ្ឋទេ ។
- ត្រូវសរសេរឈ្មោះពូជ និងថ្ងៃខែច្រូតកាត់ដាក់នៅលើបាវ ។





សំរាប់ព័ត៌មានបន្ថែមសូមធ្វើការទាក់ទង ការិយាល័យរុក្ខជំរើសវិទ្យា មជ្ឈមណ្ឌលបណ្តុះបណ្តាល និងព័ត៌មាន ការិយាល័យផែនការ សហប្រតិបត្តិការ និងពាណិជ្ជកម្ម នៃវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា នៅតាមបណ្តោយផ្លូវជាតិលេខ ៣ សង្កាត់ប្រទះឡាង ខណ្ឌដង្កោ រាជធានីភ្នំពេញ ឬតាមប្រអប់សំបុត្រលេខ 0១ ភ្នំពេញ, ទូរសព្ទ័លេខ:( ៨៥៥-២៣ )២១៩ ៦៩២-៤

ទូរសារលេខ: ( ៨៥៥-២៣ ) ២១៩ ៨00　ទូរអក្ខរ: cardi@cardi.org.kh　វែបសាយ: www.cardi.org.kh

PBREED@cardi.org.kh　TRIN@cardi.org.kh　HUNYADANA@cardi.org.kh